ព្រឹទ្ធសភារដ្ឋវ៉ាស៊ីងតោន
ព្រឹទ្ធសមាជិក Don Benton
17th Legislative District

ថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ២០១៦

ឯកឧត្តម ហ៊ុន សែន
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
រាជធានីភ្នំពេញ

នាយករដ្ឋមន្ត្រី ហ៊ុន សែន ជាទីគោរព

ខ្ញុំមានបំណងសរសេរជូនឯកឧត្តម ដើម្បីជម្រាបជូនអំពីភាពអាម៉ាសរបស់ខ្ញុំ នៅពេលដែលខ្ញុំបានឮពីសេចក្តីសម្រេចចិត្តដែលមានចេតនាខាងនយោបាយ និងមិនទទួលបានព័ត៌មានពេញលេញ ដែលបានចេញក្នុងពេលថ្មីៗនេះ ដោយតំណាងរាស្ត្រ Alan Lowenthal ពីរដ្ឋ កាលីហ្វ័រនី ។ សេចក្តីសម្រេចចិត្តនេះ ពោរពេញទៅដោយទស្សនៈខុសឆ្គង និងការភូតកុហក់ទាំងស្រុងអំពីព្រះរាជាណាចក្រកម្ពុជា ។

ខ្ញុំមិនជឿថា តំណាងរាស្ត្រ Lowenthal បានទៅធ្វើទស្សនកិច្ចនៅកម្ពុជាទេ (ប៉ុន្តែប្រសិនបើគាត់ធ្លាប់ទៅព្រះរាជាណាចក្រកម្ពុជា គាត់ហាក់ដូចជាមិនបានយល់ដឹងច្រើនឡើយ)។ ខ្ញុំបានទៅទស្សនាប្រទេសដ៏ស្រស់ស្អាតរបស់ឯកឧត្តម ដូចឯកឧត្តមបានជ្រាបហើយ ខ្ញុំបានចំណាយពេលស្វែងយល់ពីប្រជាជនដ៏រស់រវើក ព្រមទាំងប្រវត្តិសាស្ត្រ និងវប្បធម៌ដ៏អស្ចារ្យនៃប្រទេសកម្ពុជារបស់ឯកឧត្តម ។ សេចក្តីសម្រេចចិត្តនេះបានធ្វើការទាមទារក្លែងក្លាយមួយ ឲ្យមានការបោះឆ្នោតដោយសេរី និងយុត្តិធម៌ ដោយធ្វើមិនដឹងមិនឮចំពោះការពិតដែលធ្លាប់មានការបោះឆ្នោតដោយសេរី និងយុត្តិធម៌ក្នុងរយៈពេល ៣០ឆ្នាំ ចុងក្រោយនេះ ។

រដ្ឋបាលរបស់ឯកឧត្តមក៏បានការពារប្រទេសកម្ពុជាពីការគ្រប់គ្រងបែបកុម្មុយនីស្ត និងសង្គមនិយម ដែលអាចធ្វើឲ្យមានការប៉ះពាល់ធ្ងន់ធ្ងរដល់សេរីភាព និងសន្តិសុខរបស់ពលរដ្ឋកម្ពុជាដែលបានទទួលក្រោមការដឹកនាំរបស់ឯកឧត្តម ។

ប្រសិនបើពលរដ្ឋនៃប្រទេសកម្ពុជាមានកង្វល់ និងចង់ឲ្យមានការផ្លាស់ប្តូរនៅក្នុងច្បាប់ដែលគ្រប់គ្រងប្រទេសរបស់គេនោះ គេមានសេរីភាពដើម្បីដោះស្រាយបញ្ហាទាំងនោះតាមរយៈសមាជិករដ្ឋសភាដែលត្រូវបានជ្រើសតាំងតាមរយៈការបោះឆ្នោតដោយសេរីនោះ ។ នេះគឺរបៀបដែលរដ្ឋាភិបាលសេរីត្រូវធ្វើ ។

ការរំដើបរំជួលសង្គមក្នុងប្រទេសណាមួយ ជាពិសេសក្នុងប្រទេសតូចតាចដូចជាប្រទេសកម្ពុជា នឹងបណ្តាលឲ្យមានការបាត់បង់វិនិយោគបរទេស និងមានផលប៉ះពាល់អាក្រក់ដល់សេដ្ឋកិច្ច ដែលនឹងធ្វើឲ្យអ្វីៗទាំងអស់កាន់តែអាក្រក់ទៅសម្រាប់ប្រជាពលរដ្ឋគ្រប់រូប ។ ស្ថិរភាព និងសន្តិសុខ មានសារៈសំខាន់ណាស់ ចំពោះការថែរក្សាលទ្ធិប្រជាធិបតេយ្យ និងទំនុកចិត្តពីដៃគូពាណិជ្ជកម្មបរទេស ។ គឺស្ថិរភាពនេះហើយ ដែលបាននាំកម្ពុជា ឲ្យសម្រេចបាននូវជោគជ័យថ្មីៗជាច្រើននាពេលកន្លងនេះ ។

ខ្ញុំសូមអបអរសាទរសារជាថ្មីជូនចំពោះឯកឧត្តម ដែលបានថែរក្សាប្រទេសអោយមានសេរីភាព សុវត្ថិភាព និងវិបុលភាពក្នុងអំឡុងពេល ៣០ ឆ្នាំចុងក្រោយនេះ ។ សេដ្ឋកិច្ច និងគុណភាពនៃជីវភាពរស់នៅសម្រាប់ប្រជាជនកម្ពុជាគ្រប់រូប បានកើនឡើងជាលំដាប់ក្រោមការដឹកនាំរបស់ឯកឧត្តម ដែលជាមូលហេតុនាំឲ្យឯកឧត្តម ត្រូវបានជាប់ឆ្នោតជាថ្មីបន្តទៀតដោយសម្លេងភាគច្រើន បើទោះបីជាមានការភូតកុហក់ និងយុទ្ធនាការបំភ្លៃព័ត៌មានរបស់ពួកអ្នករិះគន់ក៏ដោយ ។

ជាការគួរឲ្យសោកស្តាយ យុទ្ធនាការបំភ្លៃព័ត៌មាននេះ បានបោកប្រាស់មនុស្សមួយចំនួន ដូចជាសមាជិកសភា Lowenthal ឲ្យជឿថា រដ្ឋាភិបាលរបស់ឯកឧត្តម បានសង្កត់សង្កិនប្រជាពលរដ្ឋរបស់ខ្លួន ។

ឯកឧត្តម និងខ្ញុំ ក៏ដូចជាប្រជាជនកម្ពុជាភាគច្រើនដែលមានការគិតគូរពេញលេញ ដែលនឹងបន្តបោះឆ្នោតជូនឯកឧត្តមសារជាថ្មី បានដឹងថាគ្មានអ្វីប្រសើរជាងការពិតនោះទេ ។ ការដឹកនាំដ៏ឈ្លាសវៃ និងច្បាស់លាស់របស់ឯកឧត្តម មានសារៈសំខាន់ណាស់ចំពោះការដឹកនាំប្រជាជនកម្ពុជា ក្នុងអន្តរកាលពីរបបប្រល័យពូជសាសន៍ដ៏សែនខ្ទេចខ្ទាំក្នុងទស្សវត្ស ៧០ មកកាន់សករាជថ្មីនៃវិបុលភាពខាងសេដ្ឋកិច្ច និងសេរីភាពបុគ្គល ។

ខ្ញុំនឹងបន្តចែករំលែកការពិតនៃជោគជ័យរបស់ឯកឧត្តម និងសេរីភាពដ៏ធំធេងដែលពលរដ្ឋកម្ពុជាបានទទួល ជាមួយនឹងសហការីរបស់ខ្ញុំក្នុងរដ្ឋាភិបាល និងក្នុងវិស័យឯកជន ដូចដែលខ្ញុំបានបន្តលើកទឹកចិត្ត ការធ្វើវិនិយោគនៅក្នុងប្រទេសដ៏អស្ចារ្យរបស់ឯកឧត្តម ។

ដោយស្មោះស្ម័គ្រ

( ហត្ថលេខា )

ព្រឹទ្ធសមាជិក Don Benton (R)